Australian Embassy

Cambodia

# សេចក្តីប្រកាសព័ត៌មានរួម

ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

## អូស្ត្រាលី និងកម្ពុជា រួមគ្នាជំរុញសមភាពយេនឌ័រក្នុងវិស័យឧស្សាហកម្ម និងសហគ្រាសធុនមីក្រូ តូច និងមធ្យម

ថ្ងៃនេះ ស្ថានទូតអូស្ត្រាលី និង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ អំពីផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ឆ្នាំ ២០២៣-២០២៨។

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ក្រសួងក្នុងការដាក់បញ្ចូលការបញ្ជ្រាបយេនឌ័រ ទៅកាន់កិច្ចការងារនានា និងធ្វើការឆ្ពោះទៅសម្រេចបានសមភាពយេនឌ័រនៅក្នុងការងាររបស់ក្រសួង។ ការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះ មានសារៈសំខាន់ក្នុងការឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរបរិបទសង្គម ចំណុចអាទិភាព និងជាពិសេសដើម្បីអោយស្របទៅតាមយុទ្ធសាស្ត្របញ្ចកោណ សម្រាប់អាណត្តិទី៧ នៃរាជរដ្ឋាភិបាលថ្មី។

សិក្ខាសាលានេះ ប្រព្រឹត្តទៅ ក្រោមអធិបតីភាព ឯកឧត្តម ចាស្ទីន វ៉ាយអេត ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និង ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សហគ្រាសធុនតូច និងមធ្យម សមាគមធុរកិច្ច អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធនានា ក៏បានចូលរួមក្នុងសិក្ខាសាលានេះផងដែរ។

ឯកឧត្តម ហែម វណ្ណឌី បានមានប្រសាសន៍ថា៖ "ក្រសួងប្តេជ្ញាក្នុងការជំរុញសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមនៅក្នុងការងាររបស់យើង។ ការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះ គឺជាជំហានមួយដ៏សំខាន់ឆ្ពោះទៅរកការសម្រេចគោលដៅនេះ។"

ឯកឧត្តម ហែម វណ្ណឌី បានបន្ថែមទៀតថា៖ "តាមរយៈការប្រកាន់យកគោលការណ៍បរិយាបន្ន យើងក៏នឹងចាប់យកសក្តានុពលដែលមិនទាន់បានប្រើប្រាស់នៅក្នុងសហគមន៍របស់យើង និងរួមចំណែកកាន់តែប្រសើរឡើង ដល់យុទ្ធសាស្ត្របញ្ចកោណ ដែលផ្តោតលើកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងនិរន្តរភាព"។

ឯកឧត្តម ចាស្ទីន វ៉ាយអេត បានមានប្រសាសន៍ថា៖ "យើងពិតជាមានមោទនភាពណាស់ ក្នុងការធ្វើជាដៃគូជាមួយក្រសួងលើគំនិតផ្តួចផ្តើមដ៏សំខាន់មួយនេះ។ យើងជឿជាក់ថា ផែនការយុទ្ធសាស្ត្រនេះ នឹងជួយដល់ស្ត្រីអោយទទួលបានអត្ថប្រយោជន៍ប្រកបដោយសមធម៌ ពីសកម្មភាពសេដ្ឋកិច្ចកម្ពុជា។ ។ អូស្ត្រាលី ប្តេជ្ញាជួយដល់កម្ពុជា ក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយភាពធន់ បរិយាបន្ន និងនិរន្តរភាព"។

សិក្ខាសាលានេះ ត្រូវបានគាំទ្រដោយកម្មវិធី ភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

- ស្ថានទូតអូស្ត្រាលី៖ Media.Cambodia@dfat.gov.au
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ media@misti.gov.kh
- កម្មវិធី CAPRED: លោក ឃុត ស៊ននិមល ប្រធានគ្រប់គ្រងជាន់ខ្ពស់ ផ្នែកទំនាក់ទំនង
  អ៊ីម៉ែល៖ sornnimul.khut@capred.org ǀ ទូរស័ព្ទ៖ ០៩២ ៥៦៣ ៤៧៤